# ...យន្តការអន្តរជាតិក្នុងការលុបបំបាត់




ធិការនៃអនុសញ្ញា ស៊ី ដ គឺពាក្យបណ្តឹងអាចដាក់ដោយបុគ្គល ឬក្រុម ឬជា តំណាងដោយមានការយល់ព្រមពីសាម៉ីខ្លួនជាលាយលក្ខណ៍អក្សរ។ ពាក្យបណ្តឹងត្រូវតែសរសេរជាលាយលក្ខណ៍អក្សរ និងជាភាសាអង់គ្លេស (មិនមែនជាលិខិតអនាមិក) ហើយបង្ហាញពីជំហាននានា និងដំណោះស្រាយដែលបានប្រើប្រាស់ក្នុងប្រទេស និងការភ្ជាប់ឯកសារយោង ដែលជាច្បាប់ថតចម្លង ហើយចុងក្រោយគឺការស្នើសុំដំណោះស្រាយជាក់លាក់។

ពិធីសារបន្ថែមនេះ អាចប្រើប្រាស់បានលុះត្រាតែបណ្តឹងនេះបានប្រើអស់នូវដំណោះស្រាយទាំងអស់ដែលអាចរកបាននៅក្នុងប្រទេស ឬក៏ដំណោះស្រាយនៅក្នុងប្រទេសមានការពន្យារពេលយូរ និងមិនសមហេតុផល ឬមិនទំនងជានឹងផ្តល់ដំណោះស្រាយប្រកបដោយប្រសិទ្ធភាព។ ពាក្យបណ្តឹងត្រូវស្ថិតនៅក្រោមវិសាលភាពនៃអនុសញ្ញានេះ ហើយត្រូវតែមានហេតុផលសមស្របសម្រាប់ការប្តឹងទាមទារសិទ្ធិ។ បណ្តឹងរបស់អ្នកមិនត្រូវបានគណៈកម្មាធិការអន្តរជាតិណាមួយផ្សេងទៀតកំពុងតែពិនិត្យពិចារណានោះទេនៅពេលអ្នកដាក់ពាក្យបណ្តឹងនេះទៅ ស៊ី ដ ។

ចុងចោទនៅក្នុងការប្តឹងទៅកាន់គណៈកម្មាធិការ ស៊ី ដ គឺការប្តឹងរដ្ឋភាគីដែលមានអំណាច អធិបតេយ្យភាព ដែលគេអាចទាមទារឲ្យទទួលខុសត្រូវ/ មានគណនេយ្យភាព។ រាល់ពាក្យបណ្តឹងទាំងអស់ត្រូវបញ្ជាក់ឲ្យបានច្បាស់ថា តើរដ្ឋភាគីទទួលខុសត្រូវយ៉ាងដូចម្តេចខ្លះចំពោះការរំលោភបំពានដែលត្រូវបានចោទប្រកាន់តាមរយៈការអនុវត្តសកម្មភាពអ្វីមួយ ឬខកខានមិនបានធ្វើសកម្មភាព មិនថាការធ្វើសកម្មភាព ឬការខកខានធ្វើសកម្មភាពនេះធ្វើឡើងដោយស្ថាប័នរដ្ឋ ស្ថាប័នឯកជន ឬបុគ្គលនោះទេ។ រដ្ឋាភិបាលមិនជាប់កាតព្វកិច្ចផ្លូវច្បាប់ចំពោះអនុសាសន៍របស់គណៈកម្មាធិការនេះទេ ក៏ប៉ុន្តែរដ្ឋាភិបាលគួរតែគោរពតាមអនុសាសន៍ទាំងនោះ។

រដ្ឋភាគីនៃ OP-CEDAW ត្រូវទទួលយកគំនិតយោបល់ និងអនុសាសន៍នានារបស់គណៈកម្មាធិការនេះ។ ក្រៅពីការពារជនរងគ្រោះ និងការស្តារឡើងវិញនូវសិទ្ធិរបស់ពួកគេ គោលបំណងសំខាន់របស់ពិធីសារបន្ថែមនេះ គឺដើម្បីជំរុញឲ្យមានការធ្វើកំណែទម្រង់ទូលំទូលាយ សំដៅកែលំអរ និងការអនុវត្តបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិនៅថ្នាក់ជាតិ។

បន្ទាប់ពីមានការចេញអនុសាសន៍របស់គណៈកម្មាធិការ ស៊ី ដ គឺមិនមានការប្តឹងឧទ្ធរណ៍ ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការឡើយ ដូច្នេះទស្សនៈយល់ឃើញរបស់គណៈកម្មាធិការនេះគឺមានលក្ខណៈស្ថាពរ។ ជារួមមក ស៊ី ដ ជាយន្តការមួយសម្រាប់ស្ត្រីក្នុងការទាមទារសិទ្ធិរបស់ខ្លួនពីការរំលោភបំពាន។ ដូច្នេះនៅពេលដែលស្ត្រីប្រឈមមុខនឹងការរើសអើង ឬអំពើហិង្សាណាមួយ ហើយពួកគេមិនអាចរកដំណោះស្រាយណាមួយសមស្របក្នុងប្រទេសរបស់ខ្លួន ពួកគេគួរតែដាក់ពាក្យបណ្តឹងទៅកាន់គណៈកម្មាធិការ ស៊ី ដ ព្រោះនៅពេលគណៈកម្មាធិការរកឃើញថាពិតជាមានការរំលោភបំពានសិទ្ធិមែននោះ មិនត្រឹមតែបុគ្គលផ្ទាល់ខ្លួននោះទេ ដែលទទួលបានយុត្តិធម៌ ប៉ុន្តែប្រព័ន្ធនៅក្នុងរដ្ឋភាគីទាំងមូលក៏នឹងមានការកែទម្រង់៕

**បោះពុម្ពផ្សាយដោយ**

**អាសយដ្ឋាន: ផ្ទះលេខ៣-៤ ផ្លូវលេខ៣៣៩ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ**
**លេខទូរស័ព្ទ: ០១៧ ២២៩ ៥០០**
**អ៊ីមែល: communication.wic@gmail.com**
**គេហទំព័រ: www.wic.unitedsisterhood.org**



ព្រឹត្តិបត្រ
ចេញផ្សាយខែមិថុនា ឆ្នាំ២០១៧

# ទំព័រកម្មករ

ឆ្អឹងខ្នងសេដ្ឋកិច្ចជាតិ វីរភាពគួរចងចាំ

លេខទី ៥-៦

## ធាតុពិតនៃឆ្អឹងខ្នងសេដ្ឋកិច្ចជាតិ



ធាតុពិតនៃឆ្អឹងខ្នងសេដ្ឋកិច្ចជាតិប្រសូតឡើងពីស្នាដៃកម្មការិនីកម្មកររោងចក្រកាត់ដេរប្រមាណ៣៨នាក់ ដែលជាការសិក្សាស្រាវជ្រាវពីស្ថានភាពរស់ នៅរបស់កម្មការិនីកម្មករមានគោលបំណងធ្វើឲ្យមានការយល់ដឹងកាន់តែច្បាស់ពីលក្ខខណ្ឌរស់នៅ និងការទទួលបានសេវាសង្គមជាមូលដ្ឋានរបស់ពួកគាត់។ ម្យ៉ាងវិញទៀតក៏ធ្វើឲ្យមានការយល់ដឹងទូលំទូលាយពីផលប៉ះពាល់នៃលក្ខខណ្ឌរស់នៅទៅលើការអភិវឌ្ឍ និងជីវិតរស់នៅប្រកបដោយភាពថ្លៃថ្នូររបស់ពួកគាត់ផងដែរ។ គោលបំណងចុងក្រោយក្នុងការស្រាវជ្រាវនេះ គឺបោះពុម្ពផ្សព្វផ្សាយ និងប្រើប្រាស់ទិន្នន័យដែលប្រមូលបានសម្រាប់ធ្វើការតស៊ូមតិឲ្យមានភាពប្រសើរឡើងទៅលើសិទ្ធិនិងលក្ខខណ្ឌរស់នៅរបស់ពួកគាត់។

បន្ទាប់ពីចាប់ផ្តើមមានការជួបប្រជុំគ្នាកំណត់ពីគោលបំណងនៅក្នុងការសិក្សាស្រាវជ្រាវហូតដល់មានការបង្កើតកម្រងសំណួរដើម្បីចុះសម្ភាសន៍ កម្មការិនី កម្មករ បានសម្រេចលើកយកបញ្ហាធំៗបី ដែលពួកគាត់ជួបប្រទះមកសិក្សា រួមមានបញ្ហាអនាម័យ និងសុខភាព បញ្ហាសន្តិសុខ និងសុវត្ថិភាព និងបញ្ហាស្ថានភាពបន្ទប់រស់នៅពួកគាត់។ បញ្ហាចម្បងទាំងនេះបានឆ្លុះបញ្ចាំងពីយុទ្ធនាការដើម្បីទាមទារសិទ្ធិស្ត្រីទទួលបានសេវាសង្គមជាមូលដ្ឋានរបស់សម្ព័ន្ធបងប្អូនស្រី។

ក្រុមអ្នកស្រាវជ្រាវដែលជាកម្មករកម្មការិនីរោងចក្រខិតខំសហការគ្នាយ៉ាងសស្រាក់សស្រាំក្នុងការចុះសម្ភាសន៍កម្មការិនីកម្មករតាមបន្ទប់ជួលរបស់ពួកគេ ទោះបីជាមានឧបសគ្គក៏ពួកគាត់នៅតែជំនះធ្វើរហូតទាល់តែការសម្ភាសបានបញ្ចប់ និងទទួលបានជោគជ័យ។ ជំហានបន្ទាប់ពីការសម្ភាសកម្មការិនី កម្មករ ពួកគាត់បានធ្វើការពិភាក្សាក្រុមបន្ថែមទៀត ដើម្បីឲ្យការសិក្សាស្រាវជ្រាវនេះមានលក្ខណៈពេញលេញ។

ដោយមានការសម្របសម្រួលបច្ចេក

» តទៅទំព័រ ២

## បទពិសោធរបស់កម្មករក្នុងការលើកយកវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលជាលើកដំបូង




កម្មការិនី កម្មកររោងចក្រអ៊ឹមវ៉េកាត់ដេរអន្តរជាតិ MV3 កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៧ បានដាក់លិខិតទៅនាយកដ្ឋានវិវាទការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីស្នើសុំឲ្យមានការដោះស្រាយវិវាទរបស់កម្មការិនី កម្មករនៅអគារ A ដែលរោងចក្របានព្យួរការងាររបស់ពួកគេជាបន្តបន្ទាប់។

រោងចក្រ MV បានព្យួរការងារ កម្មការិនីកម្មករអគារ A ផ្លូនៗគ្នា ពេលគឺនៅចុងឆ្នាំ ២០១៥ ព្យួររយៈពេលមួយខែ និងដើមឆ្នាំ ២០១៦ ព្យួររយៈពេលមួយខែកន្លះ គឺចាប់ពីថ្ងៃទី១៦ ខែកុម្ភៈ រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ ក្រោមហេតុផលមិនមានការបញ្ជាទិញ។ ប៉ុន្តែផ្អែកទៅលើស្ថានភាព ជាក់ស្តែងកម្មការិនី ស៊ឹម សុផា ជាតំណាងមួយរូបរបស់កម្មករបានអះអាងថា ការលើកឡើងរបស់ក្រុមហ៊ុនគឺមិនត្រឹមត្រូវទេ ព្រោះអគារស្វ័យប្រវត្តិនៅក្នុងរោងចក្រដែលដំណើរការ២៤ម៉ោងក្នុងមួយថ្ងៃ នៅតែមានសកម្មភាពរីឯអគារ៥ជាន់ និងអគារ C កម្មការិនី កម្មករនៅតែមានការងារធ្វើ។ ដោយសារហេតុផលនេះទើបកម្មការិនី កម្មករសម្រេចចិត្តដាក់លិខិតស្នើសុំការជួយធ្វើអន្តរាគមន៍ពីនាយកដ្ឋានវិវាទការងារ។

បន្ទាប់ពីដាក់លិខិតទៅនាយកដ្ឋានវិវាទការងារ មន្ត្រីខាងនាយកដ្ឋានបានធ្វើការច្រានចោលដោយអះអាងថា វិវាទនេះផុតពីដែនកំណត់របស់ខ្លួន ព្រោះវិវាទនេះធ្លាប់ត្រូវបានសហជីពដាក់ម្តង រួចមកហើយ

» តទៅទំព័រ ២

« **ធាតុពិតនៃឆ្អឹងខ្នង**

ទេសក្នុងការបំលែងទិន្នន័យពី Ms. Excel ដែលកម្មការិនី កម្មករបានបញ្ចូលព័ត៌មាន។ ក្រុមស្រាវជ្រាវនេះបានធ្វើការវិភាគ និងសរសេររបាយការណ៍ផងដែរ។

នៅពេលរបាយការណ៍បានបញ្ចប់ និងបោះពុម្ពផ្សាយរួចរាល់ ក្រុមនេះបានពិភាក្សាគ្នាពីផែនការនៅក្នុងការដាក់សម្ពោធ។ ក្រុមអ្នកស្រាវជ្រាវបានប្រើប្រាស់គំនិតច្នៃប្រឌិតរបស់ខ្លួនក្នុងការបង្ហាញពីលទ្ធផលដែលខ្លួនរកឃើញ នៅពេលសម្ពោធរបាយការណ៍។ ក្រុមនេះបានចែកគ្នាជាបីក្រុម ទៅតាមផ្នែកដែលបានសិក្សា ដោយក្រុមខ្លះបានប្រើប្រាស់គំនូរដែលគូរផ្ទាល់ដៃ និងមានបន្ថែមតួលេខទៅបទបង្ហាញរបស់ខ្លួន ហើយក្រុមខ្លះទៀតដែលអាចប្រើប្រាស់កុំព្យូទ័របាន ពួកគាត់បានប្រើកម្មវិធី Ms.Power Point ដើម្បីធ្វើបទបង្ហាញ។ លើសពីនេះកម្មការិនីមួយរូបបានតែងបទចម្រៀងដើម្បីឆ្លុះបញ្ចាំងពីស្ថានភាព និងរបកគំហើញនៃការសិក្សាផងដែរ។

ទោះបីជាការសិក្សាស្រាវជ្រាវត្រូវបានបញ្ចប់ ប៉ុន្តែក្រុមអ្នកស្រាវជ្រាវនេះនៅ តែបន្តសកម្មភាពរបស់ខ្លួនក្នុងការចែកចាយនិងប្រើប្រាស់ឯកសារនេះ ដើម្បីធ្វើការតស៊ូមតិជាមួយអ្នកពាក់ព័ន្ធនានា ដើម្បីធ្វើឲ្យស្ថានភាពរស់នៅរបស់ពួកគាត់មានភាពកាន់តែប្រសើរឡើង។ កម្មការិនី កម្មករបានចំណាយកម្លាំងកាយចិត្តទាំងស្រុង ក្នុងការធ្វើឲ្យស្នាដៃនេះលេចចេញជារូបរាងឡើង។



ធាតុពិតនៃឆ្អឹងខ្នងសេដ្ឋកិច្ចជាតិបានផ្តួចផ្តើមធ្វើឡើងដោយសមាគមមណ្ឌលព័ត៌មានកម្មករ កម្មការិនី កម្មករ រោងចក្រក្រោមជំនួយបច្ចេកទេសរបស់អង្គការ Focus on the Global South និង WaterAid ។ ការសិក្សាធ្វើឡើងនៅតំបន់បីគឺ តំបន់ទឹកថ្លា តំបន់ពោធិ៍សែនជ័យ និងតំបន់ចាក់អង្រែក្រោម ដោយមានការសម្ភាសកម្មការិនី កម្មករ ១៦៥នាក់។ អគារសំណាកដែលបានជ្រើសរើសក្នុងការសិក្សានេះ គឺជាអគារដែលមានបន្ទប់ចន្លោះពី ៥០បន្ទប់ដល់ ៣០០បន្ទប់។ របាយការណ៍នេះបានបញ្ចប់រួចរាល់ និងដាក់សម្ពោធនៅថ្ងៃទី២៨ មេសា ឆ្នាំ២០១៧ ដោយមានការចូលរួមពីកម្មការិនី កម្មកររោងចក្រ កាត់ដេរ អាជ្ញាធរមូលដ្ឋាន វិស័យឯកជន ម្ចាស់បន្ទប់ជួល និងអង្គការដៃគូសរុបប្រមាណជា ១០០នាក់៕

---

« **បទពិសោធរបស់កម្មករ**

ហើយលទ្ធផល គឺខាងរោងចក្របានឈ្នះ។ ដូច្នេះនាយកដ្ឋានមិនអាចដោះស្រាយបញ្ហាជាលើកទីពីរនោះទេ។ ដោយមិនអស់ចិត្តទៅនឹងសេចក្តីសម្រេចនេះ កម្មការិនី កម្មករបានឯកភាពគ្នានៅក្នុងការដាក់លិខិតទៅនាយកដ្ឋានអធិការកិច្ចការងារ និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ស្របពេលដាក់លិខិតទៅនាយកដ្ឋានអធិការកិច្ចការងារ ច្បាប់សហជីពត្រូវបានអនុម័ត ដែលតម្រូវឲ្យកម្មករត្រូវមានសំលេងចំនួន៣០ភាគរយ នៃចំនួនកម្មករសរុបទើបអាចមានភាពជាតំណាង ក្នុងការដាក់លិខិតវិវាទរួម។

ក្រោយពីប្រមូលស្នាមមេដៃ៦៥១ស្នាមមេដៃ នាយកដ្ឋានអធិការកិច្ចការងារបានបញ្ជូនវិវាទនេះទៅនាយកដ្ឋានវិវាទការងារ។ នាយកដ្ឋានវិវាទការងារបានហៅតំណាងរោងចក្រ និងតំណាងកម្មករទៅសម្រុះសម្រួលគ្នា ប៉ុន្តែតំណាងរោងចក្រនៅតែប្រកាន់ជំហរមិនផ្តល់សំណងដល់កម្មករ។ ជាចុងក្រោយនាយកដ្ឋានវិវាទការងារបានសម្រេចបញ្ជូនវិវាទនេះទៅកាន់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដើម្បីដោះស្រាយ។ មុននឹងដល់ថ្ងៃឡើងសវនាការតំណាងកម្មករមានការត្រៀមខ្លួនយ៉ាងខ្លាំង។ កម្មករ ណុំ វណ្ណេត បានលើកឡើងថា៖ «ពួកយើងបានត្រៀមឯកសារពង្រឹងសមត្ថភាព ក៏ដូចជាស្មារតីជាពិសេស គឺមានគោលជំហរច្បាស់លាស់ និងមានភាពជាម្ចាស់ការលើខ្លួនឯង»។

ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៧ កម្មករនិងតំណាងរបស់ខ្លួនបានចូលសវនាការដើម្បីការពារពាក្យបណ្តឹងរបស់ខ្លួន។ ទោះបីជាមានការត្រៀមខ្លួនរួចជាស្រេច និងមានឯកសារយោងគ្រប់គ្រាន់ ប៉ុន្តែជាលទ្ធផលកម្មករនៅតែចាញ់នៅក្នុងរឿងនេះ។

កម្មការិនី ស៊ិន ពិសី បានឲ្យដឹងថា៖ «ទោះបីត្រៀមខ្លួនជាស្រេចថា នឹងទទួលយកគ្រប់លទ្ធផល ប៉ុន្តែនៅពេលយើងទទួលបានសេចក្តីសម្រេចរបស់អាជ្ញាកណ្តាលដែលកាត់ក្តីឲ្យយើងចាញ់ យើងនៅតែមានអារម្មណ៍ខកចិត្ត ហើយអ្វីដែលយើងមិនអស់ចិត្តនោះគឺគាត់អត់មើលភស្តុតាងថ្មីដែលយើងមាន និងដាក់ជូននោះទេនៅក្នុងសេចក្តីបង្គាប់របស់គាត់ គឺគាត់យោងតែលើសេចក្តីបង្គាប់ចាស់»។ ស្រដៀងគ្នានេះដែរ វណ្ណេត បានលើកឡើងថា៖ «ពួកយើងខំអស់ពីកម្លាំងកាយ កម្លាំងចិត្ត ខំប្រឹងទាំងយប់ទាំងថ្ងៃ ប៉ុន្តែលទ្ធផលបែរជាយើងចាញ់...យើងអស់ជំនឿលើពួកគាត់ ដូច្នេះបើជួបបញ្ហាទៀត ធ្វើម៉េចយើងអាចយករឿងនោះទៅជួបពួកគាត់បាន?»

នៅក្នុងដំណើរការរឿងនេះកម្មការិនី កម្មករបានធ្វើការស្វែងយល់អ្វីថ្មីៗជាច្រើនជាពិសេសទាក់ទងនឹងប្រព័ន្ធច្បាប់។ កម្មការិនី ស៊ឹម សុផា៖ «អ្វីដែលខ្ញុំរៀនសូត្របាន គឺខ្ញុំបានដឹងពីប្រព័ន្ធផ្លូវច្បាប់ដែលមិនបម្រើឲ្យកម្មករ និងដឹងពីនីតិវិធីក្នុងការដោះស្រាយវិវាទ»។



# យន្តការអន្តរជាតិក្នុងការលុបបំបាត់ការរើសអើងស្ត្រីភេទ

អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (ស៊ី ដ CEDAW) បានចូលជាធរមាននៅកម្ពុជានៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩២។ តាមរយៈអនុសញ្ញានេះបានឲ្យនិយមន័យនៃការរើសអើងប្រឆាំងនឹងស្ត្រីភេទថា ជាការបែងចែក ការផាត់ចេញ ឬការរឹតត្បិតណាមួយផ្អែកលើភេទដែលមានអានុភាព ឬមានបំណងធ្វើឲ្យខូចខាត ឬធ្វើឲ្យមោឃៈភាពនូវការទទួលស្គាល់ ការអាស្រ័យផល ឬការអនុវត្តដោយស្ត្រី។ រដ្ឋភាគីទាំងអស់ (ប្រទេសដែលជាភាគីនៃអនុសញ្ញា CEDAW) ចាំបាច់ត្រូវតែអនុវត្តតាមបទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះដើម្បីលើកស្ទួយ និងការពារសិទ្ធិស្ត្រី ដើម្បីបញ្ចប់ការរើសអើង ហើយពួកគេត្រូវរាយការណ៍ជូនគណៈកម្មាធិការតាមកាលកំណត់ពីវិធានការនានាក្នុងការអនុវត្តអនុសញ្ញានេះ។ បន្ទាប់មកគណៈកម្មាធិការផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលសម្រាប់ចាត់វិធានការបន្ថែមទៀត។

ស៊ី ដ បានបង្កើតឲ្យមានពិធីសារបន្ថែមឈ្មោះថា ពិធីសារបន្ថែមទៅលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (OP-CEDAW) ដែលបានអនុញ្ញាតឲ្យមានបណ្តឹងឯកត្តបុគ្គលដែលអះអាងថាសិទ្ធិរបស់គេត្រូវបានរំលោភបំពាន។ គណៈកម្មាធិការ ស៊ី ដ អាចទទួលបណ្តឹងបែបនេះបានតែពីបណ្តាប្រទេសណាដែលបានផ្តល់សច្ចាប័នលើពិធីសារបន្ថែមនេះប៉ុណ្ណោះ។ OP-CEDAW បានចូលជាធរមាននៅកម្ពុជានៅថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០១០។

អនុសញ្ញា ស៊ី ដ មិនបានលើកឡើងជាក់លាក់អំពីអំពើហិង្សាលើស្ត្រីនិងក្មេងស្រីនោះទេ ប៉ុន្តែអនុសាសន៍ទូទៅលេខ ១២ (ពិនិត្យលើមាត្រា ២ ៥, ១១, ១២ និងមាត្រា ១៦) និង ១៩ បញ្ជាក់ថាអនុសញ្ញានេះដាក់បញ្ចូលអំពើហិង្សាលើស្ត្រី និងបានផ្តល់អនុសាសន៍លម្អិតដល់រដ្ឋភាគី។ អំពើហិង្សាលើស្ត្រី ចែកចេញជា អំពើហិង្សាផ្លូវកាយ អំពើហិង្សាផ្លូវភេទ អំពើហិង្សាសេដ្ឋកិច្ច និងអំពើហិង្សាផ្លូវចិត្ត។

បើយើងក្រឡេកមើលលើស្ថានភាពបច្ចុប្បន្នរបស់ស្ត្រីនៅក្នុងវិស័យវាយនភណ្ឌកាត់ដេរនៅកម្ពុជាបញ្ជាក់ឲ្យឃើញថា ស្ត្រីដែលជាកម្មការិនីកំពុងប្រឈមនឹងអំពើហិង្សាដូចជា៖ អំពើហិង្សាផ្លូវកាយ គឺការធ្វើការតាមចំនួនកំណត់ដែលមានចំនួនខ្ពស់ នាំឲ្យប៉ះពាល់ដល់សុខភាព។ អំពើហិង្សាផ្លូវភេទរួមមាន ការបៀតបៀនផ្លូវភេទ ការប៉ះពាល់មិនសមស្រប ឬដែលគេមិនចង់បានជាដើម។ អំពើហិង្សាសេដ្ឋកិច្ច គឺការបង្ខំឲ្យថែមម៉ោង ការផ្តល់ប្រាក់ឈ្នួលមិនស្របតាមច្បាប់ ការប្រើប្រាស់កិច្ចសន្យាខ្លី ការបញ្ឈប់ពីការងារដោយមិនសមហេតុផល។ អំពើហិង្សាផ្លូវចិត្តដូចជា ការគំរាមកំហែង ការបន្ទុះបង្អាប់ ការប្រៀបធៀប ការដាក់សំពាធផ្លូវចិត្ត ការប្រមាថមើលងាយ។

នីតិវិធីដាក់ពាក្យបណ្តឹងទៅគណៈកម្មា

» តទៅទំព័រ ៤

## សកម្មភាពរបស់សមាគមមណ្ឌលព័ត៌មានកម្មករនិងសម្ព័ន្ធបងប្អូនស្រីចូលរួមអបអរសាទរទិវាសិទ្ធិនារីអន្តរជាតលើកទី១០៦ជាមួយអង្គការដៃគូនានា





១. សកម្មភាពចូលរួមអបអរសាទរជាមួយគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ ក្រោម ប្រធានបទ «វីរភាពស្ត្រីដើម្បីសន្តិភាព និងវឌ្ឍនភាព»

២. សកម្មភាពចូលរួមអបអរសាទរជាមួយអង្គការ ActionAid Cambodia ក្រោមប្រធានបទ «រាត្រីស្រមោលសអបអរទិវាសិទ្ធិនារី»